01166719

**E1/357.1**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Nov-2015, 08:00
CMS/CFO: Sann Rada

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥**

**ម៉ោង ១៤:៤៩នាទី**

**សវនាការលើកទី៣៣៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា រ៉ូប៊ីនី្ទ ក្រូហ្វត៍ *(Ms.Robynne CROFT)*

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d’ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ស៊ាន ស៊ង់ (2-TCW-868) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សាន ស៊ន់** (2-TCW-868)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ ទំព័រ ១
សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........................................ ទំព័រ ៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[១៤:៤៩:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-CTW-868 ដែលជាសាធារណៈជាអតិបរមាតាមដែលអាចធ្វើទៅបាន។ ហើយផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសំឡេង-រូបភាព ចេញទៅទីកន្លែងដែលធ្លាប់បានផ្សព្វផ្សាយចេញទៅក្រៅមានសាធារណជន មានកន្លែងបន្ទប់សម្រាប់អ្នកសារព័ត៌មាន និងវីដេអូផ្ទៃក្នុងដូចករណីធម្មតា។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក ស៊ាន ស៊ីង៖**

**ឆ៖** ខ្ញុំបាទសូមគោរពលោកប្រធាន ខ្ញុំបាទឈ្មោះ ស៊ាន ស៊ីង។

**ស៖** "ស៊ីង" ហ្នឹង សរសេរម៉េច? លោកចេះអក្សរទេ? ស៊ីង ហ្នឹងដែលឈ្មោះរបស់លោកហ្នឹងសរសេរយ៉ាងម៉េច?

**ឆ៖** សក់ "ី" ពីលើ ដល់ "ង" "៊" – ស៊ីង។

**ស៖** អរគុណ ច្បាស់លាស់ហើយ។ ហើយតើលោកកើតនៅថ្ងៃខែឆ្នាំណា លោកស៊ីង ចាំទេ?

**ឆ៖** ខ្ញុំអត់បានចាំ។ ចាំតែអាយុ។

**ស៖** អាយុក៏បានដែរ។ នាពេលនេះ តើលោកអាយុប៉ុន្មានហើយ រហូតដល់ថ្ងៃ -- ដល់ពេលនេះ?

**ឆ៖** អាយុ ៥៥។

សៈ អរគុណហើយលោក ស៊ាន ស៊ង់។ តើទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

ឆៈ ខ្ញុំបាទនៅភូមិតាអួរស ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប។

សៈ អរគុណ។ ចុះទីលំនៅបច្ចុប្បន្ន តើលោករស់នៅទីកន្លែងណា?

ឆៈ នៅភូមិតាអួរស។

សៈ ភូមិតាអួរស នៅភូមិសាស្ត្រ ភូមិឃុំអី ស្រុកអី ខេត្តអ្វីបច្ចុប្បន្នេះ?

ឆៈ ភូមិតាអួរស ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប។

[១៤:៥៣:២២]

សៈ បាទ អរគុណ។ ហើយលោកប្រកបមុខរបបរកស៊ីធ្វើអ្វីសព្វថ្ងៃ?

ឆៈ មុខរបបនេសាទ។

សៈ ចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោកឈ្មោះគាត់ឈ្មោះអី?

ឆៈ ឪពុកបង្កើតខ្ញុំបាទឈ្មោះ ឈួន ស៊ាន។ ម្ដាយបង្កើតឈ្មោះ វ៉ាញ លឹម។

សៈ អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

ឆៈ ប្រពន្ធខ្ញុំឈ្មោះ តាប់ ឡម។ កូនមានចំនួនប្រាំនាក់។

សៈ អរគុណលោក ស៊ង់។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿង០០២ នេះទេ។ តើត្រឹមត្រូវដែរឬទេ?

ឆៈ ត្រឹមត្រូវ។

សៈ ចុះលោកបានស្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយឬនៅមុនពេលលោកចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

ឆៈ រួចហើយ។

[១៤:៥៤:៥៨]

សៈ បាទ អរគុណ។ ជាតទៅនេះ យើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក ស៊ង់ ក្នុងឋានៈលោកជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើ

អត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច លោក ស៊ង់ ក្នុងឋានៈលោកជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធ-ភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិអម្បាញ់មិញនេះ។

[១៤:៥៥:៤៧]

ហើយក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់ជួប មានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក ស៊ង់ តើលោកធ្លាប់បានឆ្លើយសក្ខីកម្ម ឬកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក ហើយបើសិនបើមាន ធ្វើប៉ុន្មានដង ធ្វើនៅកន្លែងណាខ្លះ?

**ផ៖** មាន។ ប៉ុន្តែប៉ុន្មានដង ខ្ញុំដូចអត់ចាំ។

**ស៖** ហើយកាលដែលលោកផ្តល់សេចក្តីសម្ភាសន៍ហ្នឹង ធ្វើនៅកន្លែងណាដែរ លោកចងចាំទេ ទីកន្លែងដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត?

**ផ៖** នៅទីកន្លែងវត្តខ្សាច់។

**ស៖** បាទ អរគុណ ហើយនៅមុនពេលចូលមក ចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល បានអាន ឬក៏ស្តាប់ការអានឲ្យស្តាប់នូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្ម កាលពីពេលមុន នៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំដែរឬទេ?

**ផ៖** បានអាន។

[១៤:៥៧:៣៤]

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន ថាតើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ ពិតជាត្រឹមត្រូវ ឬស៊ីចង្វាក់គ្នា ស្របគ្នា ទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នក

ស៊ើបអង្កេតកាលពីពេលមុន នៅវត្តខ្សាច់នោះដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ស៊ាន ស៊ង់ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៤:៥៨:៣៤]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វាំងសង់ ដេវីល។ ខ្ញុំនឹងសួរសំណួរលោក។ តាំងនាមការិយាល័យសហព្រះរាជអាជ្ញា សូមអរគុណដែលលោកមានវត្តមាននៅទីនេះ។ សូមឱ្យលោកឆ្លើយឱ្យបានពេញលេញទៅនឹងសំណួររបស់ខ្ញុំ។ ជាពិសេស ពាក់ព័ន្ធនឹងអ្វីដែលកើតឡើងនៅវត្តនោះ។ ប្រសិនបើលោកមិនយល់សំណួរ សូមលោកសូមឱ្យខ្ញុំសួរឡើងវិញ។ ខ្ញុំចង់ដឹងថា លោកធ្វើអ្វីនៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ក្នុងរបបខ្មែរក្រហម? លោករស់នៅកន្លែងណានៅសម័យនោះ ហើយលោកធ្វើការនៅកន្លែងណា?

**លោក ស៊ាន ស៊ង់៖**

**ឆ៖** សម័យនោះ ខ្ញុំនៅកងចល័ត ច្រូតស្រូវ។

[១៤:៥៩:៥៤]

**ស៖** លោកច្រូតស្រូវនោះ នៅកន្លែងណា ក្នុងឃុំអី ស្រុកអី ភូមិអី?

**ឆ៖** ខ្ញុំច្រូតស្រូវនោះ នៅឃុំសង្វើយ ភូមិយាង។

**ស៖** លោកនៅទីនោះ ពេញមួយរបបខ្មែរក្រហមតែម្តង ឬក៏យ៉ាងម៉េច?

ធ៖ ខ្ញុំនៅទីនោះ ទីលំនឹងអត់នៅនឹង សិនគេដកទៅឲ្យធ្វើការឯនេះសិន គេដកទៅច្រូតអីនោះ។

ស៖ ក្នុងពេលលោកនៅឃុំសង្វើយ ភូមិយាង តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំដែលដឹកនាំដោយមេឃុំ មេភូមិ ឬមេកងចល័តដែរឬទេ?

ធ៖ អត់។

ស៖ ក្នុងពេលនោះ មានធ្នកថ្មីមករស់នៅក្នុងភូមិសង្វើយហ្នឹងដែរឬទេ?

ធ៖ មាន។

[១៥:០១:៥៥]

ស៖ មានច្រើនទេ ហើយពួកអ្នកថ្មីហ្នឹងរស់នៅលាយឡំគ្នាជាមួយនឹងអ្នកចាស់ ឬក៏រស់នៅដាច់ដោយឡែកពីគេ?

ធ៖ អ្នកថ្មីនោះរស់នៅលាយឡំជាមួយគ្នាទាំងអស់។

ស៖ ក្រោយថ្ងៃទី១៧ មេសា ១៩៧៥ ក្នុងចំណោមអ្នកថ្មី តើខ្មែរក្រហមមានស្រាវជ្រាវស្វែងរកថា អ្នកណាជាអតីតទាហាន ឬមន្ត្រីរដ្ឋការនៃរបប លន់ នល់ ដែរឬទេ?

ធ៖ កន្លែងខ្ញុំអត់មាន។

ស៖ ក្នុងចំណោមប្រជាជនថ្មី មានអ្នកណាខ្លះជាជនជាតិចាម ឬវៀតណាមដែរឬទេ?

ធ៖ មានជនជាតិវៀតណាម មួយគ្រួសារ។

ស៖ លោកអាចរៀបរាប់ឈ្មោះសមាជិកគ្រួសារវៀតណាមហ្នឹងបានទេ?

ធ៖ ខ្ញុំភ្លេច ចាំតែស្រីក្រមុំម្នាក់។

ស៖ ស្រីក្រមុំហ្នឹងឈ្មោះអីដែរ?

ធ៖ ឈ្មោះ ចាន់ថា។

ស៖ ក្រៅពីគ្រួសាររបស់ ចាន់ថា តើមានជនជាតិវៀតណាមផ្សេងទៀតរត់នៅក្នុងភូមិហ្នឹងតាំងពីយូរណាស់មកហើយ ដែលរស់នៅជាប្រចាំថ្ងៃដូចជាអ្នកចាស់អ៊ីចឹងដែរ មានអ៊ីចឹងទេ?

ធ៖ អត់មានទេ។ ក្នុងភូមិនោះ មានតែមួយគ្រួសារ។

ស៖ ចុះនៅក្នុងភូមិផ្សេងទៀតនោះ ក្រៅពីភូមិរបស់លោកនោះ មានគ្រួសារជនជាតិវៀតណាមរស់នៅទេ?

[១៥:០៥:០០]

**ឆ៖** ខ្ញុំមិនសូវដឹងដែរ ក៏ប៉ុន្តែដល់ពេលគេប្រមូល មិនដឹងគេយកមកពីណា ពីណី។

**ស៖** លោកធ្លាប់ឮគេនិយាយថា នៅក្នុងស្រុកជីក្រែង នៅពេលណាមួយនោះ គេធ្វើបញ្ជើជនជាតិវៀតណាមដែរឬទេ?

**ឆ៖** អត់ដែរឮ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីហេតុការណ៍ ដែលជាមូលហេតុដែលគេកោះហៅលោកមកទីនេះ។ តើមានការសម្លាប់រង្គាលជនជាតិវៀតណាមក្នុងវត្តខ្សាច់ ក្នុងឆ្នាំ១៩៧៨ដែរឬទេ? លោកអាចរៀបរាប់អំពីហេតុការណ៍ដែលបានកើតឡើងនៅវត្តខ្សាច់នោះបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វិចទ័រ កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

តើសំណួរនេះសួរជារបៀបណាទៅវិញ? តើមានការសម្លាប់រង្គាលមែនទេនៅក្នុងឆ្នាំ១៩៧៨?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំមិនដឹងថាជាជំទាស់ ឬគ្រាន់តែជាការកត់សម្គាល់ទេ ខ្ញុំអាចរៀបចំសំណួរខ្ញុំឡើងវិញបាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** តើមានហេតុការណ៍អ្វីកើតឡើងនៅក្នុងវត្តខ្សាច់នៅឆ្នាំ១៩៧៨ មានហេតុការណ៍អ្វីធ្ងន់ធ្ងរកើតឡើងនៅវត្តហ្នឹងទេ នៅឆ្នាំហ្នឹង?

**លោក ស៊ាន ស៊ង់៖**

**ឆ៖** នៅឆ្នាំនោះ ខ្ញុំនៅកងចល័ត ថ្ងៃនោះខ្ញុំដើរទៅផ្ទះ ចៃដន្យជួប ឃើញ។

[១៥:០៧:៥៤]

**ស៖** លោកឃើញអ្វីខ្លះឲ្យប្រាកដ?

**ឆ៖** ខ្ញុំឃើញគេវាយជនជាតិវៀតណាម ដាក់អន្លង់។

**ស៖** យើងនឹងត្រឡប់មកនិយាយលម្អិតអំពីហេតុការណ៍ដែលបានកើតឡើងនេះ ក៏ប៉ុន្តែជាដំបូងនេះ ខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងវត្តខ្សាច់។ នៅវត្តនោះ នៅចន្លោះឆ្នាំ៧៥-៧៩ តើមានព្រះសង្ឃ មានការ

រៀបចំពិធីបុណ្យសាសនានៅវត្តហ្នឹងទេ?

ឆ៖ វត្តនោះ កាលដែលខ្ញុំនៅជិតហ្នឹងនោះ គឺអត់មានព្រះសង្ឃ។

ស៖ ហេតុអ្វីបានជាមិនមានព្រះសង្ឃ ឬក៏មិនមានការរៀបចំពិធីបុណ្យសាសនាព្រះពុទ្ធនៅក្នុងវត្តហ្នឹង?

ឆ៖ អត់ដឹង។

ស៖ អ៊ីចឹងចន្លោះពីឆ្នាំ៧៥-១៩៧៩ គេយកទៅវត្តហ្នឹងទៅធ្វើអ្វីដែរ?

ឆ៖ វត្តនោះ គឺដាក់កងចល័តនៅ រួចហើយ -- ប៉ុន្តែនៅអត់យូរ នៅប្រហែលជាបួនដប់ថ្ងៃកន្លះខែ គឺដកចេញ។

[១៥:១០:០៩]

ស៖ ចុះលោកផ្ទាល់ លោករស់នៅក្នុងវត្តហ្នឹងដែរឬទេ?

ឆ៖ ខ្ញុំនៅក្រៅ បាទ។

ស៖ តើមានរបងព័ទ្ធជុំវិញវត្តនុ៎ងដែរឬទេ?

ឆ៖ មួយពេលនោះ មានខ្លះ អត់ខ្លះ។

ស៖ តើរបងដែលមានខ្លះហ្នឹង ធ្វើពីអីដែរ? ធ្វើពីស៊ីម៉ង់ត៍ បេតុង ឬក៏ធ្វើពីឈើដែលមិនសូវរឹងមាំ?

ឆ៖ ធ្វើពីឈើ មិនសូវរឹងមាំ។

ស៖ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីរយៈពេលដែលមានការសម្លាប់មនុស្សដែលលោកបានឆ្លើយថាលោកបានឃើញ។ នៅក្នុងឆ្នាំ១៩៧៨ ដែលលោកថាបានឃើញហេតុការណ៍សម្លាប់មនុស្សនោះ លោកអាចបញ្ជាក់បានថា ជា។ពេលណា ជារដូវប្រាំង ឬក៏ជារដូវវស្សា?

ឆ៖ រដូវវស្សា។

ស៖ ប្រហែលជាប៉ុន្មានខែ មុនពេលវៀតណាមវាយចូលមកស្រុកខ្មែរយើង?

ឆ៖ អត់បានចាំ។

ស៖ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ E3/9335 នៅទំព័រ២ ជាភាសាទាំងបី លោកបាននិយាយថា ហេតុការណ៍ហ្នឹងកើតឡើងនៅខែវិច្ឆិកា ឆ្នាំ១៩៧៨។ ហើយនៅក្នុងកំណត់ហេតុមួយទៀត គឺ E3/7890 នៅទំព័រ២ ទាំងបីភាសាដូចគ្នា លោកបានឆ្លើយថា ការសម្លាប់មនុស្សនុ៎ះ គឺកើតឡើងនៅក្នុង

ឆ្នាំ៧៨ ក្នុងរដូវច្រូត ប្រហែលជាខែកញ្ញា ឬខែតុលា។ ដូច្នេះ ខ្ញុំសូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ថា ហេតុការណ៍ដែលលោកបានឃើញនៅវត្តហ្នឹង កើតឡើងនៅរដូវវស្សា ឬក៏រដូវច្រូត?

**ឆ៖** ព្រោះរដូវនោះ រដូវច្រូត មើលខ្ញុំដើរមកលុយទឹកតាមស្រែ។

**ស៖** សូមអររគុណ។ តើលោកឃើញអ្វីខ្លះពីការចាប់ប្រមូលផ្ដុំជនជាតិវៀតណាមនេះ?

**ឆ៖** ខ្ញុំឃើញគេប្រមូលផ្ដុំយកទៅដាក់ក្នុងវត្ត នៅក្នុងសាលាហោត្រៃ។

**ស៖** ខ្ញុំសូមនិយាយតាមដំណាក់កាល។ ឥឡូវនេះ ខ្ញុំនិយាយមុនពេលសម្លាប់ គឺនិយាយអំពីពេលដែលគេនាំជនជាតិវៀតណាមទៅកាន់វត្ត គឺពេលដែលគេទៅចាប់ខ្លួន ហើយប្រមូលមកវត្ត។ លោកបានឃើញផ្ទាល់ភ្នែកអំពីការចាប់ជនជាតិវៀតណាមណាមួយទេ?

[១៥:១៤:៥០]

**ឆ៖** អត់បានឃើញ ស្រាប់តែឃើញនៅក្នុងវត្តតែម្ដង។

**ស៖** សូមអរគុណ។ នៅក្នុងកងចល័តរបស់លោក តើមានគេចាប់ខ្លួនជនជាតិវៀតណាមទេ?

**ឆ៖** នៅក្នុងកងចល័តខ្ញុំគេដកនារី ឈ្មោះ ចាន់ថា ម្នាក់។

**ស៖** ពេលណាដែលលោកដឹងថាគេដកនារី ចាន់ថា នោះ? លោកស្ដាប់ឮ លោកបាន ឬក៏ទាល់តែពេលគេសម្លាប់គាត់ហើយទេបានលោកដឹង?

**ឆ៖** ព្រោះនារីនោះ និយាយប្រាប់ពេញកងចល័ត ថាគេដកយកមករៀនកាត់ដេរនៅភ្នំពេញ។

**ស៖** ក្នុងគ្រួសាររបស់ ចាន់ថា ហ្នឹង អ្នកណាជាវៀតណាម? ឪពុកម្ដាយរបស់ ចាន់ថា ឬក៏ជីតារបស់ ចាន់ថា ឬក៏ទាំងអស់គ្នាតែម្ដងសុទ្ធតែជាជនជាតិវៀតណាម?

**ឆ៖** ចាន់ថា ក៏វៀតណាម ជីតា-ជីដូនក៏វៀតណាម ទាំងបីនាក់។

**ស៖** ចាន់ថា កើតនៅប្រទេសកម្ពុជា ឬក៏នៅប្រទេសវៀតណាម?

**ឆ៖** កើតនៅប្រទេសកម្ពុជា។

**ស៖** គាត់និយាយខ្មែរដូចខ្មែរតែម្ដង ឬក៏និយាយខ្មែរតាមរបៀបវៀតណាម?

**ឆ៖** និយាយខ្មែរច្បាស់។

**ស៖** ពេលដែលគេមើលមុខគាត់ គេអាចដឹងទេ ថា ចាន់ថា ហ្នឹង មិនមែនជាខ្មែរទេ?

**ឆ៖** គេមើលដឹង។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីការដឹកជនជាតិវៀតណាមទៅកាន់វត្តខ្សាច់។ លោកដឹងទេថាគេនាំ

ជនជាតិវៀតណាមទៅវត្តខ្សាច់ហ្នឹងដោយប្រើមធ្យោបាយអី?

**ឆ៖** ខ្ញុំអត់បានឃើញ។

**ស៖** បើលោកមិនបានឃើញ តើលោកដឹងទេ លោកដឹងថាគេយកអីដឹកអ្នកទាំងអស់ហ្នឹងទៅវត្តទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញ លោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់លោកប្រធាន។ តាមពិតខ្ញុំត្រូវជំទាស់យូរមកហើយ។ ថាតើយ៉ាងម៉េចបានគាត់ដឹងថាអ្នកនោះជាជនជាតិវៀតណាម ហេតុអ្វីគេនៅទីនោះ សួរមកពីឈ្មោះ ចាន់ថា រួចហើយទៅសួរពីការសម្លាប់រង្គាល។ ដូច្នេះ ខ្ញុំយ៉ាងហោចណាស់ក៏សួរឲ្យច្បាស់ថា តើហេតុអ្វីបានជាដឹងថាអ្នកហ្នឹងជាជនជាតិវៀតណាម ដូចជាគ្មានសួរពីអំពីមូលហេតុអ្វីសោះ។

[១៥:១៩:៥៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំធ្វើតាមរបៀបជាលក្ខណៈប្រព័ន្ធ ហើយនិងជាបន្តបន្ទាប់ដើម្បីទទួលបានព័ត៌មានលម្អិតពីសាក្សី។ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តទៀតទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធសេចក្ដីជំទាស់។ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកខ្លួនឯងហ្នឹង លោកមិនដឹងទេ ក៏ប៉ុន្តែមានអ្នកណាប្រាប់លោកទេថា គេនាំជនជាតិវៀតណាមទៅវត្តខ្សាច់ហ្នឹងដោយប្រើមធ្យោបាយអីនោះ?

**លោក ស៊ាន ស៊ីង៖**

**ឆ៖** ឮគេនិយាយដែរ គេថាដឹកនឹងរទេះគោ។

**ស៖** អ្នកនិយាយហ្នឹង គាត់មានបានប្រាប់ថា អ្នកដែលគេដឹកទៅវត្តទាំងអស់ហ្នឹងសុទ្ធតែជាជនជាតិវៀតណាមទេ? ឬក៏គាត់មាននិយាយអីផ្សេងទៀត?

**ឆ៖** គាត់និយាយថាជនជាតិវៀតណាម។

**ស៖** ពេលដឹកទៅដល់វត្តហើយ ជនជាតិវៀតណាមហ្នឹង នៅក្នុងវត្តហ្នឹងអស់រយៈពេលប៉ុន្មានទៀត?

**ឆ៖** ដឹកទៅដល់ក្នុងវត្តនោះ នៅរយៈពេលប្រហែលជាដល់តែពេលសម្លាប់បណ្ដោយ ក្នុងវេលាថ្ងៃនោះ យប់នោះ។

**ស៖** ពេលថ្ងៃហ្នឹង លោកមានបានឃើញពីចម្ងាយ អំពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងវត្តហ្នឹងទេ?

**ឆ៖** អត់បានឃើញ។

**ស៖** តើលោកអាចពន្យល់បានទេថា ហេតុអ្វី ឬក៏ក្នុងកាលៈទេសៈណាដែលលោកបានឃើញការសម្លាប់ជនជាតិវៀតណាមនុ៎ង? មូលហេតុអីបានជាលោកទៅវត្តខ្សាច់នេះ?

**ឆ៖** ពេលនោះខ្ញុំដើរពីកងចល័តខ្ញុំមកចម្ងាយប្រហែលជាជាង ២០០ម៉ែត្រ។ ផ្លូវនៅអែបវត្តនោះ។ ដើរទៅឮសម្រែកកងរំពងទៅ ក៏ខ្ញុំក៏ឆៀងឈប់លបមើល។

**ស៖** លោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេ លោកឮសំឡេងអីខ្លះ? ហើយម៉េចបានជាលោកទៅលបមើលនុ៎ង?

**ឆ៖** ដល់ពេលខ្ញុំលបមើលទៅ ឃើញគេបណ្ដើរចេញពីក្នុងទីធ្លាកណ្ដាលវត្តនៅក្នុងហោត្រៃ។ គេបណ្ដើរចេញមក។

[១៥:២៥:០១]

**ស៖** ខ្ញុំនឹងអានទូវចម្លើយដែលលោកបានឆ្លើយជូនមន្ត្រីស៊ើបអង្កេត គឺឯកសារ E3/9335 ទំព័រ ២ ជាភាសាបារាំង, ២-៣ ជាភាសាអង់គ្លេស និង២ជាភាសាខ្មែរ។ គេសួរលោកដូចតទៅ៖ "សូមលោករៀបរាប់អំពីការសម្លាប់ជនជាតិវៀតណាមដោយពួកខ្មែរក្រហម? ប្រហែលជាម៉ោងប្រាំពីរយប់ ខ្ញុំបានឮសូរសំឡេងមនុស្សស្រែកយំយ៉ាងច្រើនចេញពីក្នុងវត្ត។ ខ្ញុំក៏បានដើរចេញពីកន្លែងកងចល័តរបស់ខ្ញុំដើម្បីចូលទៅក្នុងភូមិ ដើម្បីសាកសួរព័ត៌មានពីប្រជាជន ប៉ុន្តែប្រជាជនឆ្លើយថាមិនដឹងទេ។ ដោយមានការសង្ស័យ ខ្ញុំក៏បបួលមិត្តភក្តិរបស់ខ្ញុំ ហើយយើងក៏ដើរទៅមើល។ យើងឃើញមានភ្លើងនៅខាងក្រៅរបងវត្ត ចម្ងាយប្រហែល៥ម៉ែត្រពីរបង។" តើលោកឮសំឡេងមនុស្សស្រែកយំចេញពីក្នុងវត្តពិតប្រាកដអត់?

**ឆ៖** ពិតប្រាកដ។

**ស៖** លោកមិនគិតថា ជាការប្រថុយប្រថានទេឬ ដែលដើរទៅជិតវត្តនោះ?

**ឆ៖** ខ្ញុំដឹងថាប្រថុយប្រថានដែរ ប៉ុន្តែខ្ញុំចុះនៅក្នុងអន្លង់កុងជ្រៅ។ ត្រឹមស្មាទៅ មានផាងដូងដាក់ទទឹងៗអន្លង់កុង ខ្ញុំដើរចូលទៅក្រោម ម្ល៉ោះហើយចេះតែដើរទៅជិត ចម្ងាយប្រហែល៣០ម៉ែត្រ ខ្ញុំលបមើល។

**ស៖** ពេលដែលលោកទៅដល់ជិតវត្តនោះ ប្រហែល៣០ម៉ែត្រនោះ។ គេសម្លាប់មនុស្សហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** គេកំពុងតែសម្លាប់។

**ស៖** ពេលដែលលោកស្តាប់ឮសំឡេងមនុស្សស្រែកនៅម៉ោងប្រាំពីរយប់ ហើយនិងពេលដែលលោកលបដើរទៅមើលការសម្លាប់ហ្នឹង ឃ្លាតគ្នាប្រហែលប៉ុន្មានម៉ោងដែរ?

**ឆ៖** ខ្ញុំទៅឈរមើលនោះ ប្រហែលជាមួយម៉ោងបានខ្ញុំត្រឡប់ចេញមកវិញ។

[១៥:២៨:៣៧]

**ស៖** ចុះមិត្តភក្តិដែលទៅជាមួយលោកនោះ គាត់នៅជាមួយលោករហូតពេលដែលលួចមើលគេសម្លាប់មនុស្សហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** នៅជាមួយរហូត ពេលត្រឡប់មកវិញ មកទាំងអស់គ្នា។

**ស៖** ពាក់ព័ន្ធនឹងទីតាំងសម្លាប់មនុស្សជាក់លាក់។ ខ្ញុំចង់ដឹងថា នៅកន្លែងណានៅក្នុងវត្តនោះ កន្លែងដែលគេសម្លាប់មនុស្សនោះ? បើយើងមើលពីខ្លោងទ្វារវត្ត ឥឡូវបើលោកធៀបទៅនឹងខ្លោងទ្វារ កន្លែងដែលគេសម្លាប់ហ្នឹង នៅកន្លែងណា បើយើងធៀបទៅនឹងខ្លោងទ្វារវត្តនោះ?

**ឆ៖** នៅខាងស្តាំដៃ ដើរចូលទៅពីនេះ។

**ស៖** ការសម្លាប់ហ្នឹង សម្លាប់នៅខាងក្នុងបរិវេណវត្ត ឬក៏ខាងក្រៅរបងវត្ត?

**ឆ៖** នៅខាងក្រៅរបងវត្ត។

**ស៖** ប្រហែលជាប៉ុន្មានម៉ែត្រពីរបងវត្ត?

**ឆ៖** វាកប់ដែរ ប្រហែលជា៥-៦ម៉ែត្រពីរបងមក។

**ស៖** អម្បាញ់មិញនេះ លោកបានឆ្លើយថា លោកបានឃើញគេបណ្តើរមនុស្សពីបណ្តាល័យនៅក្នុងវត្តរហូតទៅដល់កន្លែងសម្លាប់មនុស្ស។ តើលោកឃើញទាហានប៉ុន្មាននាក់ ដែលបណ្តើរជនរងគ្រោះទាំងអស់នុ៎ងទៅកន្លែងសម្លាប់នោះ?

**ឆ៖** ប្រហែលជា១០នាក់ទៅ១២នាក់។

សៈ មានអ្នកណាព្យាយាមរត់គេចទេ?

ឆៈ អត់មាន។

សៈ កន្លែងដែលលោកលបមើលចម្ងាយ៣០ម៉ែត្រនុ៎ង លោកមើលឃើញច្បាស់ទេ លោកមើលទៅដល់កន្លែងគេសម្លាប់មនុស្សហ្នឹង ឃើញច្បាស់ក្រឡែតតែម្តងទេ?

ឆៈ ពេលនោះ គេអុជចង្កៀងម៉ាំងសុងព្យួរបំភ្លឺទៅ មើលឃើញច្បាស់។

សៈ លោកឃើញទាហានដែលសម្លាប់ហ្នឹង ហើយនិងឃើញជនរងគ្រោះហ្នឹងច្បាស់ទេ?

ឆៈ មើលឃើញច្បាស់។

សៈ លោកនៅចម្ងាយ៣០ម៉ែត្រឯណោះ អ៊ីចឹងលោកស្តាប់ឮទេ? ស្តាប់ឮនៅកន្លែងដែលគេសម្លាប់មនុស្សហ្នឹងទេ?

ឆៈ ឮ។

សៈ លោកឮអ្នកយាមនុ៎ង និយាយគ្នាទេ? ឬក៏ទាហានហ្នឹង ឮពួកគាត់និយាយគ្នាទេ?

ឆៈ ឮដែរ។

សៈ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា យោធាទាំងអស់ហ្នឹងនិយាយអំពីអ្វីដែរនៅពេលដែលពួកគេសម្លាប់មនុស្សហ្នឹង? តើគេនិយាយតែគ្នាគេទេ ឬក៏គេនិយាយទៅជនរងគ្រោះ?

ឆៈ គេនិយាយទៅជនរងគ្រោះ។

[១៥:៣៤:០៨]

សៈ អ៊ីចឹងពួកគេសួរអីដែរ ទៅជនរងគ្រោះហ្នឹង?

ឆៈ គេសួរចម្លើយ "ចិន ឬមួយយួន?"។

សៈ បាទ នៅពេលដែលពួកគេឆ្លើយថា ខ្លួនជាជនជាតិវៀតណាមហ្នឹង តើពួកអ្នកឆ្លើយថាខ្លួនជាជនជាតិវៀតណាមត្រូវបានគេយកទៅសម្លាប់ចោលដែរឬទេ?

ឆៈ អ្នកដែលឆ្លើយជនជាតិវៀតណាម គេសម្លាប់នៅមាត់អន្លង់។

សៈ ក្នុងចំណោមជនជាតិវៀតណាមដែលត្រូវបានគេសម្លាប់នោះ អ្នកដែលលោកបានឃើញគេសម្លាប់ហ្នឹង ក្រោយពេលដែលខ្លួននិយាយថាខ្លួនជាជនជាតិវៀតណាមហើយហ្នឹង អ៊ីចឹងក្នុងចំណោមពួកគាត់ហ្នឹងមានគ្រួសារទាំងមូល ទាំងស្រុងតែម្តងទេ ថាមានមនុស្សចាស់ កូនក្មេង កុមារអីជាដើមហ្នឹង មានគ្រួសារទាំងមូលតែម្តង មានទេ?

**ឆ៖** ខ្ញុំអត់ដឹងត្រង់នោះ។

**ស៖** តើលោកមានបានសង្កេតថា កុមារតូចៗ ឬក៏ទារកហ្នឹង កូនង៉ាហ្នឹងត្រូវបានគេសម្លាប់ដែរ លោកមានបានឃើញថាមានហេតុការណ៍ហ្នឹងទេ?

**ឆ៖** ឃើញដែរ។

**ស៖** នៅពេលដែលលោកឃើញគេសម្លាប់ទាំងកុមារមិនសល់នេះ តើលោកមានប្រតិកម្មយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំឈរមើល ភ័យដែរ។

**ស៖** តើមានមូលហេតុអីដែលនាំឱ្យលោកនៅឈរមើលគេសម្លាប់មនុស្សយូរយ៉ាងដូច្នេះនោះ ហេតុអ្វីបានលោកមិនរត់គេចខ្លួននៅពេលនោះ?

**ឆ៖** ព្រោះមានមនុស្សចាស់ម្នាក់ គាត់នាំខ្ញុំមើល។

**ស៖** បាទខ្ញុំយល់។ អ៊ីចឹងបានន័យថា ដោយសារមានគ្នាពីរនាក់ហ្នឹង គឺធ្វើឱ្យលោកក្លាហានហ៊ានឈរមើលគេសម្លាប់មនុស្សយ៉ាងដូច្នេះ ឬក៏យ៉ាងណា?

**ឆ៖** ព្រោះខ្ញុំមានគ្នាពីរនាក់ទៅ ម្នាក់ទៀតគាត់វាងវ័យចំណាស់ជាងខ្ញុំ បានជាហ៊ាន។

[១៥:៣៨:១២]

**ស៖** បាទ អម្បាញ់មិញនេះ លោកនិយាយថា ពួកគេចោទសំណួរទៅជនរងគ្រោះថា សួរថា តើជាចិន ឬក៏ជាវៀតណាម? តើមានអ្នកដែលឆ្លើយថា ខ្លួនមិនមែនជាវៀតណាមទេ ជាចិន។ តើមានអ្នកដែលឆ្លើយថាខ្លួនជាចិនទេ?

**ឆ៖** មាន។

**ស៖** តើយោធា គាត់មានប្រតិកម្មយ៉ាងម៉េចដែរ នៅពេលដែលអ្នកទោសនោះឆ្លើយថាខ្លួនជាចិននោះ យោធាមានប្រតិកម្មយ៉ាងម៉េចដែរ?

**ឆ៖** គេបណ្ដើរចូលទៅវិញ។

**ស៖** តើគេនាំទៅចូលទៅក្នុងវិញ ហេតុថាគេឆ្លើយថាជាជនជាតិចិន ឬក៏យោធាគេបានផ្ទៀងផ្ទាត់ព័ត៌មានហើយ ទើបឃើញថាអ្នកដែលឆ្លើយហ្នឹងពិតជាជនជាតិចិនមែន បានជានាំចូលទៅក្នុងវិញ?

**ឆ៖** ហេតុការណ៍នោះ ខ្ញុំឃើញអ៊ីចុះឯង គេនាំចូលទៅវិញ វាឮច្បាស់គេថា ខ្ញុំជនជាតិចិន ទៅគេដឹកដៃយកចូលទៅក្នុងវិញ។

**ស៖** តើលោកដឹងដែរឬទេថា នៅពេលក្រោយមកទៀត ក្រោយពេលព្រឹត្តិការណ៍ហ្នឹងទៅ អ្នកដែលឆ្លើយថាខ្លួនជាជនជាតិចិនហ្នឹង មាននៅសល់រស់រានមានជីវិតទេ?

**ឆ៖** ដែលគេបណ្ដើរយកចូលទៅក្នុងទៅ ស្រាប់ដល់ពេលផ្អាកៗ ផ្អាកបណ្ដើរមនុស្សវាយមួយភ្លែតនោះឯង ស្រាប់ឃើញជិះរទេះគោចេញមក រទេះគោបរចេញទៅក្រៅវត្តវិញ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

ខ្ញុំដឹងថាវារាងយឺតពេលបន្តិចទៅហើយ ប៉ុន្តែនេះខ្ញុំមើលទៅទស្សនិកជន ខ្ញុំឃើញអ្នកដែលៗអង្គុយមើលនេះ ប្រហែលជាប្រពន្ធរបស់សាក្សីរូបនេះផងមើលទៅ។ ដើម្បីឱ្យបង្ហាញភស្តុតាងបញ្ជាក់ឱ្យបានច្បាស់លាស់ទៅថ្ងៃណាមួយ ខ្ញុំស្នើសុំឱ្យកោះអញ្ជើញប្រពន្ធរបស់គាត់ គឺឯកសារ E3/9390 គឺថាសុំស្នើឱ្យកោះហៅប្រពន្ធរបស់គាត់នេះ មើលទៅឃើញអង្គុយនៅកន្លែងសាធារណជនអង្គុយនោះ ពីខាងក្រោយខ្នងសាក្សី។ សុំឱ្យកោះហៅ ដើម្បីសួរអំពីព្រឹត្តិការណ៍ដែលកើតឡើងនៅសៀមរាបផងដែរ។

[១៥:៤២:១២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន សុំលោកប្រធានសុំឱ្យមេធាវី កូប៉េ ឱ្យលេខកូដហ្នឹងឡើងវិញ លោកប្រធាន ព្រោះអត់បានជាភាសាបារាំង។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារ E3/9390 គឺជាកំណត់ហេតុស្ដាប់ចម្លើយ គឺមានឈ្មោះដូចប្រពន្ធរបស់គាត់ដែរ។ គឺយើងទើបតែ ដោយសារថាទើបពីពេលបើកសវនាការអសាធារណៈ ឥឡូវមកបើកសាធារណៈ ទើបឃើញមក ហើយជាការពិតហើយនៅអង្គុយក្រោយខ្នងគាត់ក្នុងកន្លែងសាធារណជនអង្គុយនេះ គឺជាប្រពន្ធគាត់។

[១៥:៤២:៥៤]

*(សម្រាករយៈពេលខ្លី)*

[១៥:៤៣:៥៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលសាកសួរស្ត្រីម្នាក់ដែលអង្គុយនៅកន្លែងសាលសវនាការជាសាធារណៈ ជននោះតើគាត់ត្រូវយ៉ាងម៉េចជាមួយនឹងសាក្សី ស៊ីង់ នេះ?

លោក ស៊ីង់ អ្នកដែលនៅខាងក្រៅសាលសវនាការនោះ នៅពីក្រោយលោកហ្នឹង ចំហៀងខាងកើតនោះនុំងវាត្រូវជាយ៉ាងម៉េចជាមួយលោក – លោក ស៊ីង់?

**លោក ស៊ាន ស៊ីង់៖**

អត់បានមើលផង។ គ្រួសារ។

**ប្រធានអង្គជំនុំ៖**

គ្រួសារ គឺប្រពន្ធរបស់លោកនោះ មែនទេ?

**លោក ស៊ាន ស៊ីង់៖**

ប្រពន្ធ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយលោកមេធាវី វ៉ិចទ័រ កូប៉េ លោកចងចាំទេថាភរិយារបស់គាត់ហ្នឹង ត្រូវជាគោលដៅនៃការអង្គជំនុំជម្រះកោះអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងអង្គហេតុការប្រព្រឹត្តចំពោះគោលដៅជាក់លាក់ចំពោះជនជាតិវៀតណាមនេះដែរឬទេ?

[១៥:៤៥:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ថាមិនមានឈ្មោះនៅលើបញ្ជីសាក្សីដែលបានកោះហៅទេ ប៉ុន្តែខ្ញុំបានដឹងថា បានផ្តល់កំណត់ហេតុស្តាប់ចម្លើយគឺ E9/9390 គាត់បានផ្តល់ ឆ្លើយ ហើយមានសំណើសុំពីភាគីមួយថា តើគាត់នេះអាចនឹងមកផ្តល់ភស្តុតាងដើម្បីឲ្យស៊ីចង្វាក់គ្នានេះដែរឬក៏យ៉ាងណា ខ្ញុំមិនច្បាស់ដែរ ខ្ញុំឃើញលោកស្រីចៅក្រម ហ្វេនស៍ គាត់ធ្វើកាយវិការអ៊ីចឹង។ ប៉ុន្តែបើសិនណាជាមានលទ្ធភាពណាមួយថា ទាំងគាត់ទាំងប្រពន្ធរបស់គាត់ពិតជាបានឆ្លើយ ដោយសារតែអ៊ីចេះ គឺចម្លើយរបស់ប្រពន្ធគាត់គឺថាវាមានជាប់ពាក់ព័ន្ធទៅនឹងកិច្ចស៊ើបអង្កេតដែលកំពុងបន្ត។ ខ្ញុំយល់ថា គួរតែបន្តធ្វើទៅថ្ងៃស្អែកទៀតទៅការសួរដេញដោលនេះ ហើយកុំឲ្យគាត់មានវត្តមាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមបញ្ជាក់ផង លោកវ៉ិចទ័រ។ តាមរយៈមក គឺមិនមានឈ្មោះនៅលើបញ្ជីសាក្សីទេ។ អ៊ីចឹងទេលោកកូប៉េ?

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយលោកស្រីចៅក្រម។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហើយតាមដែលខ្ញុំយល់ គឺថាខ្លួនលោកផ្ទាល់នៅក្នុងពេលនេះ និយាយថាគឺៗលោកៗកំពុងស្នើសុំឲ្យកោះហៅដែរឬក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

មិននៅក្នុងដំណាក់កាលនេះទេលោកស្រីចៅក្រម។ ប្រហែលជាយើងខ្ញុំនឹងពិនិត្យមើល ឲ្យស្នើសុំឲ្យកោះហៅ ស្វែងរកភស្តុតាងឲ្យវាស៊ីចង្វាក់គ្នា អ៊ីចឹងអាចស្នើសុំ ហើយវាអាចមានតម្លៃផងដែរ ពីព្រោះថា ផ្នែកពាក់ព័ន្ធទៅនឹងក្រាំងតាចាន់ គឺយើងបានស្នើសុំអង្គជំនុំជម្រះភ្លាមៗដែរ។ ខ្ញុំកំពុងពិនិត្យមើលក្រែងលោថាវាអាចមានភស្តុតាងណាមួយស៊ីចង្វាក់គ្នាជាដុំកំភួននោះ។ ប្រហែលជាគាត់ធ្លាប់បាននិយាយអំពីព្រឹត្តការណ៍ទាំងអស់នេះប្រាប់ទៅប្រពន្ធគាត់ផងក៏ថាបាន ក៏ប៉ុន្តែនៅដំណាក់កាលនេះ យើងខ្ញុំមិនទាន់សម្រេចស្នើសុំនៅឡើយទេ។ បាទ ខ្ញុំដឹងថាបញ្ហានេះមិនទាន់សម្រេចនៅឡើយទេ។

[១៥:៤៧:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកមេធាវី វ៉ិចទ័រ កូប៉េ ការដាក់លោក យើងត្រូវហាមឃាត់ដល់អ្នកណាទាំងអស់ ដែលអាចនឹងអាចផ្ដល់សក្ខីកម្មនៅទីនេះ ឬក៏យ៉ាងម៉េច ព្រោះថាគាត់នេះ អត់មាននៅក្នុងបញ្ជីសាក្សីទេនេះ។ ប្រហែលជាគាត់ -- លោកចង់និយាយថាបើសិនជាថ្ងៃណាមួយយើងកោះហៅគាត់មកស្ដាប់នៅថ្ងៃណាមួយយើងកោះហៅគាត់ឲ្យមកផ្ដល់សក្ខីកម្មនោះ ហើយយើងប្រហែលជាមិនអាចឲ្យគាត់នៅទីនេះមែន ក៏ប៉ុន្តែ បើកាលណាយើងបើកសវនាការជាសាធារណៈនេះ វាមានប្រយោជន៍ដល់ភាគីការពារក្ដីវិញទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

អ្វីដែលយើងអាចស្វែងរកឲ្យឃើញ គឺថានៅក្នុងសវនាការផ្នែកនេះគាត់បានផ្ដល់ចម្លើយរួចមកហើយដែរ ដែលមានផ្ដល់ដាក់លេខឯកសារជា E3 ហើយ ដូច្នេះមិនអាចយកគាត់ទៅប្រៀបធៀបជាមួយសាធារណជនដទៃ ដែលគ្រាន់តែមកចូលរួមតាមដានកិច្ចដំណើរការវិធីនោះទេ។ ហើយយើងខ្ញុំមិនទាន់បានសម្រេចនៅឡើយទេ ថាខ្ញុំនឹងបោះបង់ចោលនូវសក្ខីកម្មរបស់ចម្លើយរបស់គាត់ឬក៏យ៉ាងណាមិនទាន់សម្រេចដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីដោះស្រាយបញ្ហានេះ អ៊ីចឹងលោក ខ្ញុំចាប់ពីថ្ងៃស្អែកទៅលោកស្នើសុំថាកុំឲ្យគាត់មានវត្តមាននៅក្នុងបន្ទប់សាធារណៈ -- សាលសវនាការសាធារណៈនេះអ៊ីចឹងអ្នែស?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំថាសូមឈប់ឥឡូវនេះតែម្ដង ហើយចាំបន្តថ្ងៃស្អែកទៀតទៅ។

[១៥:៤៩:៣៨]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាងល៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមធ្វើការអធិប្បាយលើចំណុចនេះមួយ។ សាក្សីនេះ កាលឆ្នាំ១៩៧៥ គាត់មានអាយុ១៥ឆ្នាំ ហើយខ្ញុំគិតថាគាត់រៀបការជាមួយគ្នាក្រោយឆ្នាំ៧៩ហើយទេ យើងមើលឃើញមានឯកសារនៅក្នុងអ៊ីនធីហ្វេស នៅ ដោយមេធាវី នួន ជា។ ខ្ញុំអានឯកសារហ្នឹង ខ្ញុំគិតថាប្រហែលជាមានព័ត៌មានមួយចំនួនទាក់ទងនឹងវត្តខ្សាច់នេះ ប៉ុន្តែតាមពិតអត់មានទេ។ អ៊ីចឹងខ្ញុំគិតថាប្រហែលជាមិន -- គាត់មិនអាចមកផ្ដល់សក្ខីកម្មមកលើផ្នែកវៀតណាមនោះទេ។ ប្រហែលជាគាត់អាចមកផ្ដល់សក្ខីកម្មទាក់ទងនឹងសៀមរាបឯណោះ។ ខ្ញុំ -- គាត់អាចនិយាយបានតែពេលក្រោយពេលដែលគាត់រៀបការហ្នឹងយូរមកហើយ រយៈពេលដែលគាត់អាចនិយាយបាននោះ។ អ៊ីចឹងខ្ញុំគិតថាដូចជាមិនមានបញ្ហាអីចោទទេលោកប្រធាន។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីចៅក្រម ដែលផ្ដល់វេទិកាដល់ខ្ញុំ។ ខ្ញុំគាំទ្រការកត់សម្គាល់របស់សហភាតារបស់ខ្ញុំ ព្រោះថាយើងមិនដែលបានដាក់ឈ្មោះហ្នឹងចូលក្នុងបញ្ជីនោះទេ។ អ៊ីចឹងខ្ញុំគិតថាជាការណ៍មួយមិនសមរម្យទេដែលមិន -- យើងហាមឃាត់មិនឲ្យបុគ្គលម្នាក់ដែលមិនត្រូវបានទទួលការហាម --

មិនបានស្នើដោយភាគីទាំងអស់នោះ។ អ៊ីចឹងខ្ញុំមិនយល់ពីមូលដ្ឋាននៃការជំទាស់របស់លោកមេធាវី កូប៉េទេ ព្រោះថាភាគីអត់បានទាន់ដាក់ស្នើឱ្យរូបគាត់នៅខាងក្រៅនេះមកផង។

**ប្រធានអង្គជំនុំ៖**

បាទ ដោយមិនមានមូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ថា ភរិយារបស់សាក្សីរូបនេះដែលនៅអង្គុយតាមដានស្តាប់នូវដំណើរការសវនាការជាសាធារណៈ ស្តាប់សក្ខីកម្មសាក្សីរូបនេះនៅកន្លែងសាធារណៈនោះនៅក្នុងបញ្ជីនៃការស្នើសុំរបស់ភាគីណាមួយក្នុងការមកស្តាប់សក្ខីកម្មសាក្សីរបស់គាត់នៅក្នុងកិច្ចដំណើរការសំណុំរឿង០០២/០២ទេនោះ អង្គជំនុំជម្រះមិនមានមូលដ្ឋានសមស្របសម្រាប់ហាមឃាត់គាត់មិនឱ្យចូលមកស្តាប់នៅសវនាការជាសាធារណៈបានឡើយ។ បាទ ហេតុដូច្នេះអង្គជំនុំជម្រះគឺសម្រេចថាមិនចាំបាច់ក្នុងការបង្គាប់គាត់ឱ្យគាត់ចាកចេញពីបន្ទប់សវនាការជាសាធារណៈនាពេលនេះទេ ហើយក៏ដូចជាពេលខាងមុខដែរ ហើយការផ្អាកសវនាការក៏គឺមិនចាំបាច់ដែរ។ ដូច្នេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះបន្តទៀត។

[១៥:៥៣:០៤]

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាងលេ៖**

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ដកស្រង់នូវអ្វីដែលលោកបាននិយាយទាក់ទងទៅនឹងបុគ្គលម្នាក់ដែលជាជនជាតិចិន។ លោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/9335 ហើយទំព័រទី៣ ទំព័រទី៤ នៅគ្រប់ភាសាទាំងអស់។ លោកនិយាយដូចតទៅ៖ "បន្ទាប់មកទៀតខ្មែរក្រហមបានយកជនជាតិចិនហ្នឹងទៅវត្តហើយ ដើម្បីទៅរកបងប្អូនរបស់គេឡើងវិញ។ ហើយប្រហែលជា២០នាទីក្រោយមកទៀត ឃើញគេជួបចិនម្នាក់ទៀត សួរជនជាតិចិនម្នាក់ទៀត។ រយៈពេលប្រហែលជាមួយម៉ោងក្រោយមក ឃើញពួកកំពុងតែសម្លាប់ជនជាតិវៀតណាមនោះ ហើយមានតែគ្រួសារចិនពីរគ្រួសារហ្នឹងទេដែលត្រូវបានដោះលែងទៅវិញ។ ពួកគេបានបញ្ជាឱ្យប្រជាជននៅក្នុងភូមិនោះឱ្យដឹកតាមរទេះគោទៅភូមិកំណើតវិញទៅទាំងយប់។" អ៊ីចឹងសំណួរខ្ញុំសួរថាតើជនជាតិចិនពីរនាក់ឬក៏គ្រួសារចិនពីរគ្រួសារ? ហើយលោកនិយាយថា ពួកគាត់ត្រូវបានដោះលែងទៅវិញ។ ហើយលោកនិយាយថាពួកគាត់ហ្នឹង អម្បាញ់មិញនេះលោកនិយាយថា ត្រូវនាំទៅកន្លែងផ្សេងទៀតទេ។ អ៊ីចឹងលោកអាចបញ្ជាក់ចំណុចហ្នឹងបានទេ?

**លោក ស៊ាន ស៊ង់៖**

**ឆ៖** បាទ នាំចេញពីកន្លែងវាយដើរចូលទៅៗរកប្រពន្ធកូន។ ហើយស្រាវជ្រាវរកប្រពន្ធកូនបញ្ជូនទៅភូមិវិញទាំងយប់។

[១៥:៥៥:០៩]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំចូលមកនិយាយអំពីអ្នកសម្លាប់ដែលលោកបានសង្កេតមើលយ៉ាងហោចណាស់ក៏រយៈមួយម៉ោងដែរ លោកនិយាយថាគឺជាយោធា។ អ៊ីចឹង ខ្ញុំសួរលោកថាហេតុអីក៏លោកដឹងថា គាត់ជាយោធា ហើយដឹងថា គាត់នៅក្នុងអង្គភាពណាដែរឬទេ?

**ឆ៖** ព្រោះបានជាខ្ញុំថាគេជាយោធា ក្នុងម្នាក់គេសម្ពាយកាំភ្លើងមួយដើម។ រឿងអង្គភាព ខ្ញុំអត់ដឹង។

**ស៖** តើហ្នឹងជាលើកទី១ហើយឬ ដែលលោកឃើញយោធាទាំងអស់ហ្នឹង ឬក៏ពីមុនហ្នឹងទៅទៀតហ្នឹង លោកធ្លាប់បានឃើញពួកយោធាហ្នឹងដែរ នៅក្នុងស្រុកហ្នឹង ឬក៏នៅក្នុងមន្ទីរហ្នឹង នៅក្នុងវត្តហ្នឹង?

**ឆ៖** អត់ដែលឃើញ។

**ស៖** នៅពេលយប់ ដែលលោកមើលឃើញគេសម្លាប់ហ្នឹង លោកមានចាំឈ្មោះយោធាហ្នឹងដែរឬទេ ឧទាហរណ៍ដូចថាគេហៅគ្នាគេ យោធាទាំងអស់ហ្នឹងគេហៅគ្នាគេ ហៅឈ្មោះគ្នាគេអី ធ្វើឱ្យលោកចាំឈ្មោះហ្នឹង?

**ឆ៖** គេអត់ដែលមានហៅឈ្មោះផង គេហៅតែ “មិត្តៗ”។

**ស៖** តាមអ្វីដែលលោកឃើញពីចម្ងាយ៣០ម៉ែត្រនុ៎ង តើយោធាទាំងអស់ហ្នឹង ដែលជាពិឃាតហ្នឹងមានផឹកស្រាដែរឬទេ ពេលគេសម្លាប់មនុស្សហ្នឹង?

**ឆ៖** ផឹកស្រាដែរ។

**ស៖** នៅពេលដែលជនរងគ្រោះត្រូវបាននាំទៅដល់កន្លែងសម្លាប់ តើជនរងគ្រោះទាំងអស់ហ្នឹងមានជាប់ចំណងទេ?

**ឆ៖** អត់មានជាប់ទេ។

**ស៖** តើជនរងគ្រោះមួយចំនួននោះ មានគេបិទមុខទេ?

**ឆ៖** អត់ឃើញបិទ។

[១៥:៥៨:២៥]

**ស៖** ដោយហេតុថាជនរងគ្រោះមិនមានបិទមុខទេនៅពេលដែលខ្លួនទៅដល់កន្លែងសម្លាប់មនុស្ស នោះ។ តើប្រតិកម្មរបស់គាត់ហ្នឹងយ៉ាងម៉េចដែរនៅពេលដែលខ្លួនទៅដល់ទីនោះ ឃើញមានសាកសពផ្សេងទៀត ដែលគេទើបតែសម្លាប់ហើយនោះ តើជនរងគ្រោះហ្នឹងគាត់មានប្រតិកម្មយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំមើលពីចម្ងាយទៅ ដូចធម្មតា។

**ស៖** ពេលដែលលោកនិយាយថា ជនរងគ្រោះទាំងអស់នុ៎ងដូចធម្មតាហ្នឹង គឺលោកចង់និយាយថាយ៉ាងម៉េចដែរ ចង់និយាយថាដូចអត់មានតក់ស្លុតអីទេមុនពេលដែលគេប្រហារជីវិតនោះ ឬក៏យ៉ាងម៉េច?

**ឆ៖** ព្រោះចម្ងាយប៉ុននោះ ខ្ញុំមើលទឹកមុខគាត់អត់ដឹងទេ ថាគាត់តក់ស្លុត ឬមិនតក់ស្លុត គឺមើលអត់ដឹង។

**ស៖** តើលោកមានឮពួកគាត់ស្រែកយំ ឬក៏សម្រែកឈឺចាប់អីទេ?

**ឆ៖** នៅទីកន្លែងមាត់អន្លង់សម្លាប់ គឺអត់មាន។

**ស៖** នៅពេលដែលត្រូវ -- ពេលដែលគេសម្លាប់នុ៎ង តើជនរងគ្រោះហ្នឹង គេទុកខោអាវធម្មតាឬក៏គេដោះខោអាវចេញអស់ហើយ?

**ឆ៖** ខ្លះដោះអស់ ខ្លះនៅ ខ្លះដោះយកមកមួយកំណាត់មកលើ។

**ស៖** តើគេសម្លាប់ជនរងគ្រោះទាំងអស់នុ៎ងដោយមធ្យោបាយណា ដោយប្រើអាវុធអី ដោយប្រើឧបករណ៍អីដែរ?

**ឆ៖** គេយកគល់ពីងពង់ ប្រវែងប្រហែលជាប្រាំពីរតឹកវ៉ៃ។

**ស៖** ខ្ញុំអម្បាញ់មិញនេះ ខ្ញុំឮថាដូច៧០ម៉ែត្រ ប្រហែលជាតាមពិតទៅប្រាំពីរតឹកទេ តាមមើល៍។ ខ្ញុំមានសំណួរច្រើន មួយចំនួនត្រូវសួរទៀតដែរ ឃើញម៉ោងកាន់តែទៅមុខហើយ។ តើមានកុមារៗតូចនោះ ត្រូវបានគេវ៉ៃនឹងដំបងពីងពង់ហ្នឹងដែរឬទេ ឬក៏គេសម្លាប់ក្មេងកុមារតូចៗហ្នឹងតាមរបៀបផ្សេង?

[១៦:០២:០៧]

**ឆ៖** តាមដែលខ្ញុំឃើញ ជួនកាលគេវ៉ៃ ជួនកាលគេលើកបោះបញ្ចូល។

**ស៖** ខ្ញុំយល់ចម្លើយរបស់លោកមិនច្បាស់។ ខ្ញុំឮអម្បាញ់មិញ គឺថាមួយចំនួនគេសម្លាប់ មួយចំនួនទៀតគេបោះចូលនៅក្នុងរណ្ដៅ។ លោកចង់និយាយថា មាន -- ខ្ញុំសួរម្ដងទៀត តើលោកចង់

និយាយថាមានកុមារមួយចំនួនគេមិនសម្លាប់ កុមារមួយចំនួនទៀតគេសម្លាប់ ឬក៏លោកចង់និយាយថា របៀបសម្លាប់កុមារទាំងអស់នោះ មានច្រើនរបៀបផ្សេងៗគ្នា?

**ឆ៖** ពេលយកកុមារទៅដល់ ជួនកាលគេវៃសម្លាប់ ជួនកាលគេចាប់បោះឡើងលើធ្លាក់មកវិញ ចូលអន្លង់សន្ទប់ វៃពីលើដាក់សង្កត់ទៅទៀតស្លាប់បាត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៨ ខែតុលា ឆ្នាំ ២០១៥ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ាន ស៊ង់ បន្តបញ្ចប់ពាក់ព័ន្ធនឹងអង្គហេតុការប្រព្រឹត្តលើមនុស្សជាក្រុមគោលដៅជាក់លាក់ចំពោះជនជាតិវៀតណាម សូមភាគីជ្រាបនិងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ស៊ាន ស៊ង់ ដំណើរការសវនាការសក្ខីកម្មលោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនិងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងសូមឱ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃស្អែក ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ទាំងពីររូបមកចូលរួមសវនាការនៅថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*